បេព័ន្ធសោធននិវត្តន៍ជាតិ

1. ចំណុចសំខាន់នៃប្រព័ន្ធសោធននិវត្តន៍សាធារណៈ ៖ ប្រព័ន្ធសោធននិវត្តន៍ជាតិ

(1) ច្បាប់ប្រទេសជប៉ុនតម្រូវអោយអ្នកចុះឈ្មោះរស់នៅប្រទេសជប៉ុនទាំងអស់ដែលមានអាយុចន្លោះពី 20ឆ្នាំដល់ 59ឆ្នាំ ទោះជាមានសញ្ជាតិអ្វីក៏ដោយ ត្រូវតែចុះឈ្មោះចូលក្នុងប្រព័ន្ធសោធននិវត្តន៍ជាតិ ហើយបង់ប្រាក់ចូលរួមចំណែក។

(2) ប្រព័ន្ធសោធននិវត្តន៍សាធារណៈ (រួមទាំងប្រព័ន្ធសោធននិវត្តន៍ជាតិ) ត្រូវបានរៀបចំឡើងជាយន្តការគាំទ្រផ្នែកហិរញ្ញវត្ថុអន្តរជំនាន់។

(3) ប្រព័ន្ធសោធននិវត្តន៍សាធារណៈមិនត្រឹមតែផ្តល់ប្រាក់សោធននិវត្តន៍ជរាភាពប៉ុណ្ណោះទេ ប៉ុន្តែក៏មានផ្តល់ជាប្រាក់សោធននិវត្តន៍ជនពិការ និងប្រាក់សោធននិវត្តន៍គ្រួសារជនរងគ្រោះផងដែរ នៅពេលលោកអ្នកមានបញ្ហាហិរញ្ញវត្ថុដែលមិននឹកស្មានដល់។

(4) រដ្ឋាភិបាលជប៉ុនផ្តល់ការឧបត្ថម្ភមួយផ្នែកនៃប្រាក់សោធននិវត្តន៍។

(5) ប្រាក់ចូលរួមចំណែកសម្រាប់សោធននិវត្តន៍សាធារណៈរបស់អ្នក ជាកម្មវត្ថុនៃការកាត់បន្ថយពន្ធ ក្នុងនាមជា "ការរួមចំណែកធានារ៉ាប់រងសង្គម"។

2. ប្រាក់ចូលរួមចំណែកប្រចាំខែ

ទឹកប្រាក់វិភាគទានសម្រាប់ប្រព័ន្ធសោធននិវត្តន៍ជាតិ គឺមានចំនួន ¥16,980 ក្នុងមួយខែ ដោយគិតចាប់ពីខែមេសា ឆ្នាំ2024 ដល់ខែមីនា ឆ្នាំ2025 ។ លោកអ្នកអាចបង់ប្រាក់ចូលរួមចំណែកជាសាច់ប្រាក់ នៅតាមធនាគារនិងតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ការិយាល័យប្រៃសណីយ៍ និងផ្សារម៉ាត។ លោកអ្នកក៏អាចបង់ប្រាក់នេះ ដោយប្រើការបញ្ជូនសារធនាគារដោយស្វ័យប្រវត្តិ ដោយការបង់ប្រាក់តាមអ៊ីនធើណែត ឬដោយកាតឥណទាន។

3. អត្ថប្រយោជន៍ទទួលបានសម្រាប់សោធននិវត្តន៍ជាតិ

(1) **សោធននិវត្តន៍ជរាភាព**
ប្រសិនបើលោកអ្នកបានបង់ប្រាក់ចូលរួមចំណែកសោធននិវត្តន៍ជាតិយ៉ាងតិច 10 ឆ្នាំ ហើយបំពេញលក្ខខណ្ឌចាំបាច់នោះ លោកអ្នកនឹងទទួលបានសោធននិវត្តន៍ជរាភាពចាប់ពីអាយុ 65 ឆ្នាំឡើងទៅ។

(2) **សោធននិវត្តន៍ជនពិការ**
សោធននិវត្តន៍ជនពិការនឹងត្រូវបានផ្តល់ជូនលោកអ្នក បើលោកអ្នកធ្លាក់ខ្លួនឈឺឬរងរបួសនៅពេលលោកអ្នកទទួលបានការធានារ៉ាប់រងដោយប្រព័ន្ធប្រាក់សោធននិវត្តន៍ជាតិ ហើយជំងឺឬរបួសបណ្តាលឱ្យមានពិការភាព ដូចបានបញ្ជាក់ក្នុងតារាងពិការភាពកម្រិត 1 ឬ 2។

(3) **សោធននិវត្តន៍គ្រួសារជនរងគ្រោះ**
នៅពេលអ្នកដែលមានធានារ៉ាប់រងនៃប្រព័ន្ធប្រាក់សោធននិវត្តន៍ជាតិបានទទួលមរណភាព សោធននិវត្តន៍គ្រួសារជនរងគ្រោះនឹងត្រូវបានផ្តល់ជូនប្តីឬប្រពន្ធដែលស្ថិតក្នុងបន្ទុករបស់គាត់ដែលកំពុងមើលថែទាំកូន ឬផ្តល់ទៅអោយកូនដែលស្ថិតក្នុងបន្ទុករបស់គាត់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅ ការិយាល័យសាខា JPS ឬការិយាល័យក្រុងនៃមូលដ្ឋានរបស់អ្នក (ផ្នែកសោធននិវត្តន៍ជាតិ)។
សូ មមើលគេ ទំព័រទេយើងទនៅ https://www.nenkin.go.jp/international/index.html សេវាកម្មសោធននិវត្តន៍ជាតិ ចុច

សម្រាប់សំណួរទូទៅពាក់ព័ន្ធនឹងការធានារ៉ាប់រងនៃសោធននិវត្តន៍ សូមទូរសព្ទទៅ៖
"លេខទាក់ទងសម្រាប់ Nenkin Kanyusha" 0570-003-004 (អ្នកប្រើប្រាស់ក្នុងតំបន់)
បើលេខទូរសព្ទអ្នកចាប់ផ្តើមពីលេខ 050 សូមខលទៅ៖ 03-6630-2525 (តំលៃធម្មតា)
ម៉ោងសេវាកម្ម៖ 8:30 – 19:00 ថ្ងៃច័ន្ទ – ថ្ងៃសុក្រ
ចាប់ពីម៉ោង 9:30 ព្រឹក ដល់ម៉ោង 16:00 រសៀល សម្រាប់ថ្ងៃសៅរ៍ទីពីរនៃខែ
ថ្ងៃសម្រាកសេវាកម្ម (ក្រៅពីថ្ងៃសៅរ៍ទីពីរនៃខែ) ចាប់ពីថ្ងៃទី 29 ខែធ្នូ ដល់ថ្ងៃទី 3 ខែមករា

日本年金機構
Japan Pension Service
2407 1016 038

ការដាក់ពាក្យសុំការលើកលែងឬពន្យារពេលបង់ប្រាក់ចូលរួមចំណែកសម្រាប់សោធននិវត្តន៍ជាតិ

[一般用]

ច្បាប់ប្រទេសជប៉ុនតម្រូវអោយអ្នកចុះឈ្មោះរស់នៅប្រទេសជប៉ុនទាំងអស់ដែលមានអាយុចន្លោះពី 20ឆ្នាំដល់ 59ឆ្នាំ ទោះជាមានសញ្ជាតិអ្វីក៏ដោយហើយរស់នៅក្នុងអំឡុងពេលប៉ុន្មានក៏ដោយ ត្រូវតែចុះឈ្មោះចូលក្នុងប្រព័ន្ធសោធននិវត្តន៍ជាតិ ដែលជាប្រព័ន្ធសោធននិវត្តន៍សាធារណៈជប៉ុន ហើយបង់ប្រាក់ចូលរួមចំណែក។
បើអ្នកមានការលំបាកផ្នែកហិរញ្ញវត្ថុក្នុងការបង់ប្រាក់ចូលរួមចំណែក អ្នកអាចដាក់ពាក្យសុំប្រព័ន្ធលើកលែងឬប្រព័ន្ធពន្យារពេលការបង់ប្រាក់ចូលរួមចំណែក សម្រាប់ឆ្នាំនិមួយៗ។
យើងនឹងធ្វើការពិនិត្យសំណើរបស់អ្នកផ្អែកសំខាន់លើចំណូលពីមុនរបស់អ្នក បើមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកនឹងទទួលបានការលើកលែងឬពន្យារពេល។ តាមរយៈការធ្វើនីតិវិធីនេះ អ្នកអាចរក្សាបាននូវសិទ្ធិក្នុងការទទួលបានប្រាក់សោធននិវត្តន៍ជរាភាពនៅអនាគតនិងប្រាក់សោធននិវត្តន៍ក្នុងករណីអ្នកជួបគ្រោះថ្នាក់រងរបួសទៅជាពិការនៅពេលបច្ចុប្បន្ន។

(1) ការដាក់ពាក្យសុំការលើកលែងការបង់ប្រាក់ចូលរួមចំណែកទាំងស្រុងឬដោយផ្នែក
អ្នកអាចដាក់ពាក្យសុំការលើកលែងទាំងស្រុងឬដោយផ្នែកសម្រាប់ឆ្នាំណាមួយ ក្នុងករណីដែលចំណូលរបស់អ្នក ប្តីឬប្រពន្ធរបស់អ្នក (រួមទាំងករណីមិនរស់នៅជាមួយគ្នា) ឬមេគ្រួសារនៅឆ្នាំមុនមានចំនួនតិចជាងចំនួនកំណត់មួយ ឬមានអ្នកណាម្នាក់គ្មានការងារធ្វើ។ បើគេពិនិត្យឃើញថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកនឹងទទួលបានការលើកលែង។
សូមជ្រាបថា ក្នុងករណីលើកលែងដោយផ្នែក គឺតម្រូវអោយអ្នកបង់ប្រាក់ចូលរួមចំណែកដែលនៅសល់ បើអ្នកខកខានមិនបានបង់ចំនួននៅសល់ទេនោះ អំឡុងពេលនៃការលើកលែងដោយផ្នែកនឹងលែងមានសុពលភាព ហើយអំឡុងពេលនេះត្រូវបានចាត់ទុកជាអំឡុងពេលមិនបានបង់ប្រាក់។

(2) ការដាក់ពាក្យសុំពន្យារពេលបង់ប្រាក់ចូលរួមចំណែក
អ្នកអាចដាក់ពាក្យសុំពន្យារការបង់ប្រាក់បើអ្នកមានអាយុតិចជាង 50ឆ្នាំ (លើកលែងជាសិស្ស) ហើយចំណូលរបស់អ្នក ប្តីឬប្រពន្ធរបស់អ្នក (រួមទាំងករណីមិនរស់នៅជាមួយគ្នា) នៅឆ្នាំមុនមានចំនួនតិចជាងចំនួនកំណត់មួយ។
បើគេពិនិត្យឃើញថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកនឹងទទួលបានការពន្យារពេល។

ចំណុចសម្គាល់សម្រាប់ការដាក់ពាក្យ

- **ឆ្នាំដាក់ពាក្យ**
  - អំឡុងពេលនៃការលើកលែងឬពន្យារពេលសម្រាប់ឆ្នាំនិមួយៗគឺរាប់ពីខែ កក្កដា ដល់ខែ មិថុនាឆ្នាំបន្ទាប់។
  - <u>បើអ្នកចង់បានការលើកលែងឬការពន្យារពេលសម្រាប់ឆ្នាំបន្ទាប់ទៀត ជាទូទៅអ្នកត្រូវដាក់ពាក្យនៅរៀងរាល់ខែកក្កដា។</u>
- **<u>ការដាក់ពាក្យសម្រាប់ឆ្នាំកន្លងទៅនិងឆ្នាំបច្ចុប្បន្ន</u>**
  - សម្រាប់ឆ្នាំកន្លងទៅ៖ អ្នកអាចដាក់ពាក្យសុំការលើកលែងឬការពន្យារពេលសម្រាប់ពេលកន្លងទៅរហូតដល់ 25ខែរាប់ថយក្រោយចាប់ពីពេលដាក់ពាក្យ (បើអ្នកបានបង់ប្រាក់ចូលរួមចំណែកសម្រាប់ខែខ្លះរួចហើយសម្រាប់រយៈពេល 25 ខែនេះ ប្រាក់ចូលរួមចំណែកដែលបានបង់មិនត្រូវបានលើកលែងទេ)។
  - សម្រាប់ឆ្នាំបច្ចុប្បន្ន៖ នៅពេលអ្នកដាក់ពាក្យសុំការលើកលែងឬការពន្យារពេលសម្រាប់ឆ្នាំបច្ចុប្បន្ន វាមានប្រសិទ្ធិភាពរហូតដល់ខែ មិថុនា មានន័យថា បើអ្នកដាក់ពាក្យនៅចន្លោះខែមករានិងខែមិថុនា ការដាក់ពាក្យនេះមានប្រសិទ្ធិភាពរហូតដល់ខែមិថុនាឆ្នាំដដែល។
    ការដាក់ពាក្យម្តងមានប្រសិទ្ធិភាពសម្រាប់ 12ខែ រាប់ពីខែ កក្កដាដល់ខែមិថុនា។
    បើអ្នកចង់បានការលើកលែងសម្រាប់អំឡុងពេលវែងជាងនេះ អ្នកត្រូវធ្វើការដាក់ពាក្យច្រើនជាងម្តង។
    <u>សម្គាល់</u>៖ អ្នកអាចដាក់ពាក្យសម្រាប់ពេលកន្លងទៅរហូតដល់ 25ខែរាប់ថយក្រោយចាប់ពីពេលដាក់ពាក្យ។
    យើងផ្តល់យោបល់អោយអ្នករួសរាន់ទៅដាក់ពាក្យអោយបានឆាប់ ដើម្បីអោយអំឡុងពេលធានារ៉ាប់រងក្នុងអតីតមានសុពលភាព។បើអ្នកយឺតយ៉ាវក្នុងការដាក់ពាក្យ អ្នកអាចបាត់បង់សិទ្ធិក្នុងការទទួលសោធននិវត្តន៍ជនពិការ។
- **ឯកសារដែលយើងត្រូវការ**
  បើអ្នកដាក់ពាក្យសុំការលើកលែងព្រោះតែគ្មានការងារធ្វើ ក្សីយធន ឬបញ្ចប់ជំនួញ យើងត្រូវការឯកសារកស្តាងរួមមានលិខិតចម្លងនៃលិខិតបញ្ជាក់សិទ្ធិទទួលប្រាក់ឧបត្ថម្ភសម្រាប់អ្នកគ្មានការងារ (Koyohoken Jukyu Shikakusha Sho) ឬបង្កាន់ដៃបញ្ជាក់ការលាឈប់ពីការងារហើយមានសិទ្ធិទទួលប្រាក់ឧបត្ថម្ភសម្រាប់អ្នកគ្មានការងារ(Koyohoken Hihokensha Rishokuhyo)។ សម្រាប់ព័ត៌មានលំអិតអំពីឯកសារយោង សូមទាក់ទងទៅ ការិយាល័យក្រុងក្នុងនៃមូលដ្ឋានរបស់អ្នក ឬ ការិយាល័យសាខា JPS ។
- **<u>ឯកសារដែលយើងខ្ញុំត្រូវការ ប្រសិនបើលោកអ្នកដាក់ពាក្យស្នើសុំដោយប្រើប្រាស់ "លេខសម្គាល់ខ្លួន" ("My Number") របស់លោកអ្នក</u>**

ប្រសិនបើអ្នកដាក់ទម្រង់ រួមទាំងលេខខ្ចី់ របស់អ្នក ទៅសាលាក្រុងរបស់អ្នកជាដើម អ្នកត្រូវបង្ហាញ ប័ណ្ណ លេខខ្ចី់ របស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណ នោះទេ សូមផ្តល់ឯក សារមួយមុខ១ច្បាប់នៅក្នុង (១) និង (២) ខាងក្រោម៖
ប្រសិនបើអ្នកផ្ញើទម្រង់តាមប្រៃសណីយ៍ សូមភ្ជាប់មកជាមួយនូវច្បាប់ចម្លងទាំងសងខាងនៃប័ណ្ណ លេខខ្ចី់ របស់អ្នក។ ក្នុងករណីគ្ម ន ប័ណ្ណ សូមភ្ជាប់មកនូវច្បាប់ចម្លងមួយ មុខ១ច្បាប់នៃឯកសារនៅក្នុង (១) និង (២) ខាងក្រោម៖
(1) ច្បាប់ចម្លងមានទីកាន្ទុកូលកម្មនៃការចុះបញ្ជីស្នា ក់នៅរបស់អ្នកដែលមានលេខខ្ចី់ របស់អ្នក ឬលិខិតជូនដំណឹងពីលេខខ្ចី់ របស់អ្នក (ប្រសិនបើឈ្មោះ និងអាសយដ្ឋានដូចគ្នាជាមួយនឹងព័ត៌មានក្នុងការចុះបញ្ជីស្នា ក់នៅ) ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃលេខខ្ចី់ របស់អ្នក។
(2) ប័ណ្ណ បើកបរ ឬលិខិតឆ្លងដែន ឬប័ណ្ណ ស្នាក់នៅ ឬឯកសារដែលមានខ្លឹមសារដូចគ្នាផ្សេងទៀត ដើម្បីបញ្ជាក់ថាអ្នកជាម្ចាស់ពិតប្រាកដនៃលេខនោះ។ (សម្រាប់ ព័ត៌មានលម្អិត សូមសាកសួរទៅការិយាល័យសាខា JPS។)

កន្លែងដាក់ពាក្យ

សូមដាក់ពាក្យស្នើរសុំពេញលេញ របស់អ្នកទៅការិយាល័យក្រុងនៃមូលដ្ឋានរបស់អ្នក ឬ ការិយាល័យសាខា JPS។
អ្នកអាចផ្ញើរពាក្យស្នើរសុំតាមប្រៃសណីយ៍ផងដែរ។
សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅការិយាល័យក្រុងនៃមូលដ្ឋានរបស់អ្នក ឬ ការិយាល័យសាខា JPS ។

<u>សូមអានទំព័របន្ទាប់អំពីរបៀបបំពេញពាក្យស្នើរសុំ។</u>

របៀបបំពេញពាក្យ

គំរូ

សូមអានដោយយកចិត្តទុកដាក់អំពីរបៀបបំពេញពាក្យស្នើរសុំ ការលើកលែង/ការពន្យារពេលបង់ប្រាក់ចូលរួមចំណែកសម្រាប់សោធននិវត្តន៍ជាតិ។ សូមបំពេញដូចគំរូជាអក្សរពណ៌ក្រហម ក្នុងការបំពេញព័ត៌មាននិមួយៗក្នុងទម្រង់ ជាភាសាជប៉ុន ឬ អក្សរឡាតាំង និងលេខ(លេខអារ៉ាប់)។ សូមជ្រាបថា ក្នុងករណីដែលពាក្យស្នើរសុំមិនពេញលេញឬខ្វះទិន្នន័យចាំបាច់នោះ យើងនឹងប្រគល់ពាក្យស្នើរសុំទៅអ្នកវិញហើយពេលនោះនឹងសុំឲ្យអ្នកបំពេញទិន្នន័យជាភាសាជប៉ុន ដែលអាចនាំអោយមានការយឺតយ៉ាវដល់ដំណើរការនៃការស្នើរសុំនេះ។

បំពេញថ្ងៃខែឆ្នាំ(ឆឆឆឆ/ខខ/ថថ)ដាក់ពាក្យ
អាស័យដ្ឋានរបស់អ្នកនៅពេលដាក់ពាក្យ
ឈ្មោះរបស់អ្នកជាអក្សរឡាតាំងអោយដូចក្នុងលិខិតឆ្លងដែន។

សូមបញ្ចូល "លេខសម្គាល់ខ្លួន" 12 ខ្ទង់ (អត្តលេខរបស់អ្នកក្នុងប្រទេសជប៉ុន) ឬលេខសម្គាល់សោធននិវត្តន៍មូលដ្ឋានចំនួន 10 ខ្ទង់នៅក្នុងកូឡោនទី ①
(ចំពោះលេខសំគាល់សោធននិវត្តន៍មូលដ្ឋាន
សូមបំពេញដោយតម្រឹមខាងឆ្វេង។)

សូមបំពេញឈ្មោះរបស់លោកអ្នកចូលក្នុងកូឡោនទី ③
បំពេញឈ្មោះស្វាមីភរិយាចូលក្នុងកូឡោនទី ⑤
និងឈ្មោះមេគ្រួសារចូលក្នុងកូឡោនទី* ⑦
ប្រសិនបើជាមនុស្សខុសគ្នាពីបុគ្គលពីររូបខាងលើ។ (សូមបំពេញព័ត៌មានបច្ចុប្បន្ន បើអ្នកស្នើរសុំការលើកលែង/ពន្យារពេលសម្រាប់ឆ្នាំបច្ចុប្បន្ន។
សម្រាប់ការដាក់ពាក្យសម្រាប់ឆ្នាំកន្លងទៅ
សូមបំពេញព័ត៌មាននៃថ្ងៃចុងក្រោយនៃឆ្នាំដែលត្រូវសុំ។
ឧទាហរណ៍ថាអ្នកចង់សុំការលើកលែងសម្រាប់ឆ្នាំ 2023
សូមបំពេញឈ្មោះនីមួយៗដូចមាននៅថ្ងៃទី 30 ខែមិថុនា ឆ្នាំ2024។)
* មេគ្រួសាររបស់អ្នក (ជាទូទៅគឺអ្នកដែលរកកំរៃបានច្រើនជាងគេក្នុងគ្រួសារ)
គឺមាននៅក្នុងកំណត់ត្រាចុះឈ្មោះស្នាក់នៅប្រទេសជប៉ុន (JUMINHYO)។

សូមបំពេញព័ត៌មាននៅក្នុងកូឡោនទី ⑪ ប្រសិនអ្នក ប្ដី/ប្រពន្ធ ឬមេគ្រួសាររបស់អ្នកមានសមាជិកគ្រួសារក្នុងបន្ទុក ដែលមានអាយុចន្លោះពី 16 ដល់ 18 ឆ្នាំ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំមុនរហូតដល់ឆ្នាំដាក់ពាក្យ។
កូឡោននេះមានបីជួរ៖ ជួរទីមួយគឺសម្រាប់លោកអ្នក
ជួរទីពីរគឺសម្រាប់ស្វាមីភរិយារបស់អ្នក ជួរទីបីគឺសម្រាប់មេគ្រួសារ។
ឧទាហរណ៍ ប្រសិនបើមេគ្រួសាររបស់អ្នកមានសមាជិកគ្រួសារក្នុងបន្ទុកម្នាក់ ចូរគូសរង្វង់លើចំណងជើងនៃជួរទីបី ហើយគូសរង្វង់លើពាក្យថា "あり" (មាន) ហើយបញ្ចូលលេខ 1 ទៅក្នុងវង់ក្រចក () នៅខាងស្ដាំ។

ជាធម្មតា លោកអ្នកត្រូវដាក់ពាក្យនៅរៀងរាល់ខែកក្កដា ប្រសិនបើអ្នកមានបំណងបន្តការលើកលែង ឬការពន្យាររយៈពេល។ ប៉ុន្តែ
ដើម្បីអាចឱ្យពួកយើងត្រៀមរៀបចំសម្រាប់ឆ្នាំក្រោយសម្រាប់លោកអ្នកបាន សូមបញ្ជាក់ជម្រើសរបស់លោកអ្នកនៅក្នុងកូឡោនទី ⑬។

1. ប្រសិនបើអ្នកទទួលបានការលើកលែង ឬការពន្យាររយៈពេលពេញលេញក្នុងពេលនេះ ហើយប្រសិនបើយើងរកឃើញថាលោកអ្នកអាចនៅតែមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ក្នុងការបន្តលក្ខខណ្ឌនេះបានសម្រាប់ឆ្នាំក្រោយទៀត តើលោកអ្នកមានបំណងចង់ដាក់ពាក្យស្នើសុំការលើកលែង ឬការពន្យាររយៈពេលពេញលេញបន្តទៀតដែរឬទេ? ប្រសិនបើមិនចង់ទេ សូមគូសរង្វង់លើពាក្យថា 希望しません នៅក្នុងប្រអប់ខាងស្ដាំ។
2. ប្រសិនបើលោកអ្នកទទួលបានការពន្យាររយៈពេលសម្រាប់ឆ្នាំនេះ ហើយប្រសិនបើយើងរកឃើញថា លោកអ្នកនៅតែអាចមានសិទ្ធិក្នុងការទទួលបានការលើកលែងពេញលេញសម្រាប់ឆ្នាំក្រោយ តើលោកអ្នកមានបំណងចង់ដាក់ពាក្យស្នើសុំបន្តការលើកលែងពេញលេញនៅក្នុងឆ្នាំក្រោយដែរឬទេ? ប្រសិនបើមិនចង់ទេ សូមគូសរង្វង់លើពាក្យថា 希望しません នៅក្នុងប្រអប់ខាងស្ដាំ។

សម្រាប់ព័ត៌មានលម្អិត
សូមទាក់ទងមកកាន់ការិយាល័យសាខាសេវាកម្មប្រាក់សោធននិវត្តន៍ជប៉ុន (JPS) ឬការិយាល័យក្រុងក្នុងមូលដ្ឋានរបស់អ្នក។

នៅក្នុងផ្នែកទីមួយនៃទម្រង់ស្នើសុំនេះ ក្នុងនាមលោកអ្នកជាអ្នកដែលមានធានារ៉ាប់រង និងជាអ្នកដាក់ពាក្យសុំ លោកអ្នកត្រូវបញ្ជាក់ឱ្យបានច្បាស់ថា លោកអ្នកដាក់ពាក្យស្នើសុំការលើកលែង ឬការពន្យាររយ:ពេល។ លោកអ្នកក៏ត្រូវប្រកាសផងដែរថា ព័ត៌មានផ្ទាល់ខ្លួន ស្វាមីភរិយា និងមេគ្រួសាររបស់លោកអ្នក ត្រូវបានបំពេញពេញលេញ និងត្រឹមត្រូវ។ បន្ទាប់មក លោកអ្នកអនុញ្ញាត និងផ្ទេរសិទ្ធិឱ្យសេវាកម្មប្រាក់សោធននិវត្តន៍ជប៉ុន (JPS) និងការិយាល័យក្រុង ប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ដូចជាព័ត៌មានអំពីប្រាក់ចំណូល ដែលជាព័ត៌មានចាំបាច់ក្នុងការពិនិត្យពាក្យសុំរបស់អ្នក។



សូមបញ្ចូលលេខទូរសព្ទរបស់លោកអ្នកនៅក្នុងកូឡោនទី ②។ គូសរង្វង់លើលេខទូរសព្ទដែលលោកអ្នកប្រើប្រាស់៖ 1. សម្រាប់ទូរសព្ទនៅផ្ទះ 2. ទូរសព្ទដៃ 3. ទូរសព្ទកន្លែងធ្វើការ 4. ទូរសព្ទផ្សេងៗ។
បញ្ចូលថ្ងៃខែឆ្នាំកំណើត (ឆ្នាំ/ខែ/ថ្ងៃ) របស់លោកអ្នកនៅក្នុងកូឡោនទី ④
ហើយសូមបញ្ចូលថ្ងៃខែឆ្នាំកំណើតស្វាមីភរិយានៅក្នុងកូឡោនទី ⑥។

ប្រសិនបើលោកអ្នក ស្វាមីភរិយា ឬមេគ្រួសាររបស់លោកអ្នក រស់នៅក្រៅប្រទេសជប៉ុន គិតត្រឹមថ្ងៃទី01 ខែមករា នៃឆ្នាំដាក់ពាក្យសុំ សូមបញ្ជាក់ឈ្មោះប្រទេសនៅក្នុងកូឡោនទី ⑧។ ឧទាហរណ៍ ប្រសិនបើលោកអ្នករស់នៅក្នុងប្រទេសជប៉ុន គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ (ថ្ងៃទី1 ខែកក្កដា ឆ្នាំ2024) ដោយបំពេញពាក្យសុំសម្រាប់ឆ្នាំ2024 ហើយលោកអ្នកបានរស់នៅសហរដ្ឋអាមេរិក គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2024 សូមបំពេញឈ្មោះរបស់លោកអ្នក និង "សហរដ្ឋអាមេរិក"។
បញ្ចូលលេខសម្គាល់ខ្លួនស្វាមីភរិយារបស់អ្នក ប្រសិនបើស្វាមីភរិយារបស់លោកអ្នករស់នៅក្នុងអាសយដ្ឋានផ្សេងនៅក្នុងប្រទេសជប៉ុន គិតត្រឹមថ្ងៃដាក់ពាក្យសុំ (ថ្ងៃទី30 ខែមិថុនានៃឆ្នាំដាក់ពាក្យសុំ ប្រសិនបើដាក់ពាក្យសុំសម្រាប់ឆ្នាំចាស់)។
ប្រសិនបើអ្នក ប្ដីឬប្រពន្ធរបស់អ្នក ឬមេគ្រួសារផ្លាស់ប្ដូរទីលំនៅមក/ទៅបរទេសក្នុងអំឡុងពេលនៃឆ្នាំដាក់ពាក្យស្នើសុំនៅក្នុង ⑩, សូមបញ្ចូលឈ្មោះពាក់ព័ន្ធ កាលបរិច្ឆេទ និងប្រទេសនៅក្នុង ⑧។ (ឧទាហរណ៍ ប្រសិនបើអ្នកផ្លាស់ប្ដូរទីលំនៅពីអាមេរិកទៅប្រទេសជប៉ុន នៅថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2024 សូមបញ្ចូល "(ឈ្មោះរបស់អ្នក)បានផ្លាស់ប្ដូរទីលំនៅពីសហរដ្ឋអាមេរិក នៅ2024/11/1"។)

បញ្ចូលឆ្នាំ (បួនខ្ទង់) ដែលលោកអ្នកចង់ស្នើសុំលើកលែង ឬពន្យាររយ:ពេលដែលនឹងត្រូវទទួលបាន។ ឆ្នាំដាក់ពាក្យសុំ គឺគិតចាប់ពីខែកក្កដា រហូតដល់ខែមិថុនាឆ្នាំបន្ទាប់។ ឧទាហរណ៍ ពាក្យស្នើសុំឆ្នាំ 2024 គិតចាប់ពីខែកក្កដា ឆ្នាំ2024 ដល់ខែមិថុនា ឆ្នាំ2025។
លោកអ្នកអាចដាក់ពាក្យសុំសម្រាប់រយ:ពេលកន្លងផុតរហូតដល់ទៅ 25 ខែថយក្រោយ គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យសុំ។ ប៉ុន្តែ ប្រសិនបើលោកអ្នកបានបង់ប្រាក់វិភាគទានសម្រាប់រយ:ពេលប៉ុន្មានខែរួចមកហើយក្នុងអំឡុងពេល 25 ខែនោះ វិភាគទានដែលបានបង់រួចនឹងមិនត្រូវបានលើកលែង/បើកយកវិញបានឡើយ។

ប្រសិនបើលោកអ្នកដាក់ពាក្យសុំសម្រាប់ការលើកលែង ដោយសារតែលោកអ្នក ស្វាមីភរិយា ឬមេគ្រួសាររបស់លោកអ្នកបានបាត់បង់ការងារ ឧទាហរណ៍ លាឈប់ពីក្រុមហ៊ុន សូមបញ្ចូលកាលបរិច្ឆេទ (ឆ្នាំ/ខែ/ថ្ងៃ) បន្ទាប់ពីថ្ងៃលាឈប់មួយថ្ងៃ ឧទាហរណ៍
កាលបរិច្ឆេទគ្មានការងារធ្វើទីមួយនៅក្នុងកូឡោនទី ⑫។
បញ្ចូលព័ត៌មានរបស់លោកអ្នកនៅក្នុងជួរទីមួយ
ព័ត៌មានរបស់ស្វាមីភរិយានៅជួរទីពីរ ព័ត៌មានរបស់មេគ្រួសារនៅជួរទីបី។
ប្រសិនបើសមាជិកណាម្នាក់ ត្រូវបានធានាដោយសេវាធានារ៉ាប់រងការងារមុនលាឈប់ពីការងារ ចូរគូសរង្វង់លើពាក្យថា "あり" (មាន) ដែលនៅខាងស្ដាំនៃសញ្ញាព្រួញ ⇒ ហើយដាក់ជូនឯកសារភស្តុតាងអំពីវិសាលភាពនៃការធានារ៉ាប់រងនោះ។